**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**លេខ៖ បព ៧៧/២០២៥ កបទ.សអ** — **សេចក្ដីប្រកាសព័ត៌មាន**

# ឯកអគ្គរដ្ឋទូតរុស្ស៊ី លោក Anatoly Borovik ជួបសម្ដែងការគួរសម ជាមួយឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន

នៅព្រឹកថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានផ្លាស់ប្ដូរយោបល់ស្ដីអំពីការពង្រឹងទំនាក់ទំនងទ្វេភាគីកម្ពុជា-រុស្ស៊ី ជាមួយ ឯកឧត្តម Anatoly Borovik ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ីប្រចាំកម្ពុជា ក្នុងអំឡុងពេលឯកឧត្តមឯកអគ្គរដ្ឋទូត ជួបសម្ដែងការគួរសមនៅទីស្ដីការក្រសួង។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះចំណងមិត្តភាពប្រពៃណីយូរអង្វែងរវាងកម្ពុជា និងរុស្ស៊ី ដោយកត់សម្គាល់ពីខួបលើកទី៧០ នៃទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរនៅឆ្នាំ២០២៦។ ភាគីទាំងពីរបានឯកភាពបន្តពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីលើគ្រប់វិស័យ ដើម្បីផលប្រយោជន៍ទៅវិញទៅមក។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូនឯកអគ្គរដ្ឋទូត Anatoly Borovik អំពីស្ថានភាពធ្ងន់ធ្ងរនៃជម្លោះកម្ពុជា-ថៃ និងបានថ្លែងអំណរគុណដល់ឯកឧត្តមឯកអគ្គរដ្ឋទូត ដែលបានចូលរួមរំលែកទុក្ខចំពោះការបាត់បង់ជីវិត និងការសម្ដែងនូវសមានចិត្តអាណិតអាសូរចំពោះជនស៊ីវិលដែលរងផលប៉ះពាល់។ ភាគីទាំងពីរមានក្ដីបារម្ភដូចគ្នាលើផលប៉ះពាល់ធ្ងន់ធ្ងរនៃព័ត៌មានក្លែងក្លាយ និងព័ត៌មានមិនពិត និងបានបដិសេធចំពោះសេចក្ដីរាយការណ៍តាមប្រព័ន្ធផ្សព្វផ្សាយដែលគ្មានមូលដ្ឋាន ចោទប្រកាន់ថាពលរដ្ឋរុស្ស៊ីកំពុងបម្រើការជាទាហានស៊ីឈ្នួលនៅកម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្ដែងការកោតសរសើរចំពោះឯកអគ្គរដ្ឋទូត Anatoly Borovik ដែលបានគាំទ្រដល់ការឈប់បាញ់ជាបន្ទាន់ និងការវិលត្រឡប់ទៅរកដំណោះស្រាយដោយសន្តិវិធី។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**បានថ្លែងអំណរគុណដល់ស្ថានទូតសហព័ន្ធរុស្ស៊ី ដែលបានចូលរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងផ្ដល់ជំនួយសង្គ្រោះដល់ប្រជាជនភៀសសឹកជាច្រើនគ្រួសារ តាមរយៈកាកបាទក្រហមកម្ពុជា។

ថ្ងៃសៅរ៍ ១កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២៥

អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh